Beth Israel Lahey Health
Anna Jaques Hospital

# សេចក្តីសង្ខេបភាសាសាមញ្ញនៃគោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុ

មន្ទីរពេទ្យ Anna Jaques (AJH) ជាមន្ទីរពេទ្យសម្រាកព្យាបាលដែលមិនស្វែងរកប្រាក់ចំណេញ ត្រូវបានបង្កើតឡើងដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនក្នុងរដ្ឋ Massachusetts និងតំបន់ជុំវិញ។ មន្ទីរពេទ្យប្តេជ្ញាចិត្តក្នុងការផ្តល់សេវាវេជ្ជសាស្ត្រដល់អ្នកជំងឺ ដោយមិនគិតពីលទ្ធភាពក្នុងការទូទាត់ប្រាក់របស់ពួកគេ។ AJH ទទួលស្គាល់ថា មិនមែនអ្នកជំងឺទាំងអស់សុទ្ធតែមានធនធានហិរញ្ញវត្ថុ ដើម្បីទូទាត់វិក្កយបត្រមន្ទីរពេទ្យនោះទេ។ សេចក្តីសង្ខេបជាភាសាសាមញ្ញនេះផ្តល់នូវព័ត៌មានមូលដ្ឋាន អំពីគោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុរបស់យើង។

## គោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុរបស់ **AJH**

បុគ្គលិកប្រឹក្សាផ្នែកហិរញ្ញវត្ថុរបស់យើងនឹងជួយបុគ្គលម្នាក់ៗ ក្នុងការដាក់ពាក្យស្នើសុំកម្មវិធីធានារ៉ាប់រងសុខភាពរបស់រដ្ឋាភិបាលដែលសមស្រប និងបំពេញពាក្យស្នើសុំជំនួយផ្នែកហិរញ្ញវត្ថុដោយឥតគិតថ្លៃ។ កម្មវិធីជំនួយផ្នែកហិរញ្ញវត្ថុផ្តល់ការសង្គ្រោះបន្ទាន់ និងសេវាកម្មចាំបាច់ផ្នែកវេជ្ជសាស្ត្រផ្សេងទៀតដែលសមស្រប ដោយឥតគិតថ្លៃដល់អ្នកជំងឺដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ មិនថាអ្នកជំងឺគ្មានធានារ៉ាប់រង ឬធានារ៉ាប់រងបានតិចតួចនោះទេ ពួកគេអាចដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុបាន។ នៅពេលទទួលបានការអនុម័ត អ្នកជំងឺអាចនឹងទទួលបានជំនួយដូចខាងក្រោម ដោយផ្អែកលើសមតុល្យរបស់អ្នកជំងឺលើសេវាកម្មវេជ្ជសាស្ត្រដែលត្រូវរ៉ាប់រង៖

ការព្យាបាលដោយសប្បុរសធម៌

| កម្រិតភាពក្រីក្ររបស់រដ្ឋ | ចំនួននៃជំនួយ |
|---|---|
| នៅកម្រិត ឬក្រោម 400% | 100% |

ការលំបាកក្នុងការទូទាត់ផ្នែកវេជ្ជសាស្ត្រ
ការបញ្ចុះតម្លៃ ១០០% សម្រាប់អ្នកជំងឺដែលវិក្កយបត្រព្យាបាលរបស់គេច្រើនជាង ឬស្មើនឹង ២៥% នៃប្រាក់ចំណូលគ្រួសារសរុបរបស់ពួកគេ។
**សំគាល់៖** មន្ទីរពេទ្យមិនមែនដៃគូធានារ៉ាប់រង សហធានារ៉ាប់រង និងការកាត់កង សុទ្ធតែមិនមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុទេ។ មិនមានករណីណាដែលអ្នកជំងឺដែល ទទួលបានជំនួយហិរញ្ញវត្ថុនឹងត្រូវបានគិតថ្លៃច្រើនជាងចំនួនទឹកប្រាក់លើវិក្កយបត្រទូទៅសម្រាប់អ្នកជំងឺប្រើប្រាស់សេវាធានារ៉ាប់រងនោះឡើយ។

## វិធីដើម្បីទទួលបានឯកសារនៃពាក្យស្នើសុំ និងគោលនយោបាយជំនួយហិរញ្ញវត្ថុរបស់យើង

អ្នកអាចទទួលបានឯកសារគោលនយោបាយ និងពាក្យស្នើសុំរបស់យើងដោយឥតគិតថ្លៃ តាមមធ្យោបាយខាងក្រោម:

- គេហទំព័រ AJH៖ https://www.ajh.org/patients-and-visitors/billing-and-insurance
- ទៅកាន់ការិយាល័យពិគ្រោះយោបល់ផ្នែកហិរញ្ញវត្ថុរបស់យើងដែលមានទីតាំងនៅ៖
  មន្ទីរពេទ្យ Anna Jaques
  25 Highland Avenue
  Newburyport, MA 01950
- ស្នើសុំឯកសារឲ្យផ្ញើតាមប្រៃសណីយ៍ ឬជាអេឡិចត្រូនិកដោយទូរស័ព្ទមកលេខ (៩៧៨)៤៦៣-១១៣៤ (អ្នកក៏អាចហៅមកលេខនេះ ដើម្បីស្នើសុំជំនួយក្នុងដំណើរការដាក់ពាក្យស្នើសុំផងដែរ។)

## គោលនយោបាយ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងឯកសារសង្ខេបជាភាសាសាមញ្ញអាចរកបាននៅក្នុងភាសាជាច្រើន

គោលនយោបាយ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងឯកសារសង្ខេបជាភាសាសាមញ្ញ មានភាសាដូចខាងក្រោម៖

| | | |
|---|---|---|
| អង់គ្លេស | អេស្ប៉ាញ | បារាំង |
| អ៊ីតាលី | ចិន (សាមញ្ញ) | ចិន (ដើម) |
| ប៉័ទុយហ្កាល់ | វៀតណាម | អារ៉ាប់ |
| គ្រីអូល (ហៃទី) | ក្រិក | ខ្មែរ |
| រុស្ស៊ី | | |

## វិសាលភាពនៃគោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុ

អ្នកជំងឺត្រូវតែដាក់ពាក្យស្នើសុំកម្មវិធីធានារ៉ាប់រងសុខភាពរបស់ រដ្ឋាភិបាលក្នុងរយៈពេល ៦ ខែនៃការដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ ដើម្បីមានសិទ្ធិទទួលបានជំនួយពី AJH ។ អ្នកជំងឺ ឬ អ្នកធានាអាចដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុគ្រប់ពេលរហូតដល់ពីររយសែសិប (២៤០) ថ្ងៃ បន្ទាប់ពីទទួលបានវិក្កយបត្រអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យលើកដំបូង។

ប្រគល់ពាក្យស្នើសុំដែលបានបំពេញរួចរបស់អ្នកមក៖
មន្ទីរពេទ្យ Anna Jaques
ការិយាល័យប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុ
25 Highland Avenue
Newburyport, MA 01950

ប្រសិនបើអនុម័ត ជំនួយផ្នែកហិរញ្ញវត្ថុអាចប្រើប្រាស់បាននៅ៖

- មន្ទីរពេទ្យ Anna Jaques
- មន្ទីរពេទ្យ Addison Gilbert
- មន្ទីរពេទ្យ BayRidge
- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Beth Israel Deaconess
- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Beth Israel Deaconess Milton
- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Beth Israel Deaconess Needham
- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Beth Israel Deaconess Plymouth
- មន្ទីរពេទ្យ Beverly
- មន្ទីរពេទ្យ និងមជ្ឈមណ្ឌលវេជ្ជសាស្ត្រ Lahey
- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Lahey, Peabody
- មន្ទីរពេទ្យ Mount Auburn
- មន្ទីរពេទ្យ New England Baptist
- មន្ទីរពេទ្យ Winchester

**សម្គាល់៖** គ្រូពេទ្យមួយចំនួនមិនត្រូវបានរាប់បញ្ចូលនៅក្នុងគោលនយោបាយជំនួយហិរញ្ញវត្ថុរបស់មន្ទីរពេទ្យ Anna Jaques ទេ។ សូមចូលមើលគេហទំព័ររបស់យើង ឬទំនាក់ទំនងមកកាន់លេខ ៩៧៨-៤៦៣-១១៣៤ សម្រាប់ព័ត៌មានបន្ថែម។